**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងផែនការ**

**លេខ ០២០៨ ផ.ក**

*ថ្ងៃពុធ ១៤រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨*

# ប្រ កា ស

## ស្តីពី

## ការកែសម្រួលសមាសភាពរបស់ក្រុមការងារជាតិ សម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ។
- បានឃើញអនុក្រឹត្យ លេខ២៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតរបស់ក្រសួងផែនការ លេខ៨៨៨ ផ.ក ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការចាត់តាំងមន្ត្រីជាន់ខ្ពស់ចូលជាសមាជិកនៃក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- បានឃើញលិខិតរបស់ក្រសួងផែនការ លេខ០០១៩ ផ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៨ ស្តីពីការចាត់តាំងមន្ត្រីជំនាញចូលជាសមាជិកនៃក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- ផ្អែកតាមតម្រូវការចាំបាច់ដែលមានចែងនៅក្នុងជំពូកទី៦ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ស្តីពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។